**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១១៤៨ សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
## ស្តីពីការផ្ទេរឥណទានថវិកាមិនមែនកម្មវិធី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០, ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៧៦អនក្រ.បក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ១០១៨សហវ.ប្រក, ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូកតាមគណនីនិងអនុគណនីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- លិខិតលេខ ៣២១៩ អយក.ហវ, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៣ និងលិខិតលេខ ៣២២២ អយក.ហវ, ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៣ របស់ក្រសួងអប់រំ យុវជន និងកីឡា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855 23 724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១** : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ នូវការផ្ទេរឥណទានថវិកាមិនមែនកម្មវិធី ពី (ផ្នែកអប់រំ) ជំពូក ៦៤ ចំនួន ២.៧៩៣.៦៩៧.០០០រៀល (ពីរពាន់ប្រាំពីររយកៅសិបបីលានប្រាំមួយរយកៅសិបប្រាំពីរពាន់រៀលគត់) ជូនមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងខេត្តសៀមរាប ដូចមានបញ្ជាក់ខាងក្រោម ៖

ឯកតាពាន់រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ឆ្នាំ ២០១៣ | ឥណទាន បច្ចុប្បន្ន | ចលនាឥណទាន | | ឥណទាន ថ្មីក្រោយផ្ទេរ |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| ផ្ទេរពី ផ្នែកអប់រំ | | | | - | - | **2.793.697** | **2.793.697** | - |
| 64 | 643 | 6432 | ប្រាក់បំណាច់សម្រាប់ប្រឡង.... | 24.295.000 | 22.515.700 | - | 2.793.697 | 19.722.003 |
| ផលប្រយោជន៍ខេត្តកំពង់ចាម | | | | - | - | - | - | - |
| 64 | 642 | 6423 | ប្រាក់បំណាច់ម៉ោងបន្ថែម | 10.249.700 | 10.249.700 | 1.684.000 | - | 11.933.700 |
| ផលប្រយោជន៍ខេត្តសៀមរាប | | | | - | - | - | - | - |
| 64 | 642 | 6421 | បៀវត្សមូលដ្ឋាន | 22.818.400 | 22.818.400 | 1.109.697 | - | 23.928.097 |

**ប្រការ ២** : ឥណទានដែលបានផ្ទេរក្នុងប្រការ១ ខាងលើនេះ ត្រូវបានអនុញ្ញាតឱ្យបំពេញបន្ថែមទៅក្នុងសៀវភៅថវិការបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងខេត្តសៀមរាប នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងថវិកាឆ្នាំ ២០១៣ ដើម្បីចំណាយលើបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ម៉ោងបន្ថែម ។

**ប្រការ ៣** : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមអភិបាលខេត្តកំពង់ចាម និងឯកឧត្តមអភិបាលខេត្តសៀមរាប ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

ចម្លងជូន
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ចាម និងខេត្តសៀមរាប
- រតនាគារខេត្តកំពង់ចាម និងខេត្តសៀមរាប
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ